អង្គការអភិវឌ្ឍន៍សំលេងសហគមន៍

**គម្រោង៖** បង្កើនជីវភាពរស់នៅរបស់សហគមន៍ តាមរយៈអេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ

## របាយការណ៍ករណីសិក្សា

## សហគមន៍អេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ – អាផ្សាធរមូលដ្ឋាន

១. សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្ម ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយមានការគាំទ្រពីមន្ទីរ និងក្រសួងបរិស្ថាន។ សហគមន៍មានផ្ទៃដី ៥០៦ ហិកតា មានគណៈកម្មការ ៩ រូប (ស្រី ៣ រូប) និងមានអ្នកទទួលផលសរុប ៦២៥ នាក់។ ប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ចិញ្ចឹមសត្វ និងប្រមូលអនុផលព្រៃឈើ ខណៈមួយចំនួនធ្វើការចំណាកស្រុក។

សហគមន៍កំពុងប្រឈមមុខនឹងបញ្ហាខ្វះធនធានថវិកា ដៃគូអភិវឌ្ឍន៍ និងសមត្ថភាពបច្ចេកទេស។ បន្ថែមពីនេះ ភូមិជីពូក និងភូមិងយ រងផលប៉ះពាល់ពីរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់ទិន្នផលកសិកម្ម និងជីវភាពរស់នៅ បង្កើនហានិភ័យនៃសកម្មភាពខុសច្បាប់លើធនធានធម្មជាតិ។

## ២. ព័ត៌មានទូទៅដែលលើកឡើងដោយលោក ជួន សំអាត ជំទប់ទី១ ឃុំក្បាលទឹក

លោក ជួន សំអាត អាយុ ៥០ ឆ្នាំ រស់នៅភូមិជីពូក ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ លោកមានមុខរបរជាជំទប់ទី១ ឃុំក្បាលទឹក ហើយជាបុគ្គលមួយរូបដែលសកម្មក្នុងការចូលរួម និងគាំទ្រសហគមន៍ព្រៃធំអន្លង់ថ្ម ជាពិសេសក្នុងការអនុវត្តគម្រោង GEF ដែលបានទទួលចាប់តាំងពីឆ្នាំ ២០២៤។ លោកជំទប់ទី១បានលើកឡើងថា មុនពេលអនុវត្តគម្រោង GEF សហគមន៍មានសក្តានុពលរួចហើយ ប៉ុន្តែសមត្ថភាពរបស់សមាជិកគណៈកម្មការនៅមានកម្រិត ហើយមិនទាន់មានលទ្ធភាពរៀបចំសហគមន៍ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍បានល្អ។ ឧទាហរណ៍ មិនមានបន្ទប់ទឹក មិនបានរៀបចំកន្លែងសម្រាប់បោះតង់

ព្រៃឈើមានចំនួនតិច និងរិចរិល មិនមានទីសក្ការៈបូជា។ ដូច្នេះ សកម្មភាពការងាររបស់សហគមន៍មិនទាន់ដំណើរការល្អប្រសើរនោះទេ។




## ៣. ឆ្នាំ ២០២៤ សហគមន៍ព្រៃធំអន្លង់ថ្ម ទទួលបានការគាំទ្រពីគម្រោង GEF

នៅឆ្នាំ ២០២៤ សហគមន៍ព្រៃធំអន្លង់ថ្ម បានទទួលការគាំទ្រពីគម្រោង GEF ដែលជាឱកាសដ៏ល្អសម្រាប់ពង្រឹងសមត្ថភាព និងជំនាញបច្ចេកទេសដល់សមាជិកគណៈកម្មការ ក្នុងផ្នែកភាពជាអ្នកដឹកនាំការគ្រប់គ្រង ការសរសេររបាយការណ៍ និងការធ្វើផែនការសកម្មភាព។ លោកជំទប់ទី១ បានចូលរួមគាំទ្រ

យ៉ាងសកម្មជាមួយសមាជិកគណៈកម្មការ ក្នុងការអនុវត្តសកម្មភាពជាច្រើន ដូចជា៖ រៀបចំប្រជុំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការបម្រែបម្រួលអាកាសធាតុ និងសារៈប្រយោជន៍នៃធនធានធម្មជាតិ ចូលរួមគាំទ្រក្នុងការបង្កើតក្រុមសន្សំ គាំទ្រការរៀបចំផែនការសកម្មភាពសហគមន៍ តាមដានការអនុវត្តការងាររបស់គណៈកម្មការ បំពេញចន្លោះខ្វះខាត និងចូលរួមដោះស្រាយបញ្ហាដែលកើតឡើងឱ្យបានទាន់ពេលវេលា។ ក្រៅពីនេះ លោកជំទប់ទី១ ក៏បានសហការជាមួយសមាជិកគណៈកម្មការចុះល្បាតបង្ការបទល្មើសព្រៃឈើ ការបរបាញ់ និងការដាក់អន្ទាក់សត្វ កសាងផែនការរក្សាសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរណ៍ដែលមកទស្សនាធនធានធម្មជាតិក្នុងសហគមន៍ ហើយក៏បានចូលរួមជាមួយសហគមន៍ក្នុងការបំប៉ូសដើមឈើផងដែរ។





## ៤. ការប្រែប្រួល និងការរីកចម្រើនក្រោយទទួលបានការគាំទ្រពីគម្រោង GEF

តាមរយៈការខិតខំប្រឹងប្រែងរបស់គណៈកម្មការសហគមន៍ព្រៃធំអន្លង់ថ្ម រួមជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ សហគមន៍មានបន្ទប់ទឹកសម្រាប់ភ្ញៀវទេសចរណ៍

មានទីសក្ការៈបូជា អ្នកដឹកនាំសហគមន៍មានភាពរឹងមាំទាំងផ្នែករូបវន្ត និងអរូបវន្ត និងមានសមត្ថភាពដឹកនាំសមាជិកបានល្អប្រសើរ។ បទល្មើសព្រៃឈើមានការថយចុះ ព្រៃឈើលូតលាស់ និងស្តារឡើងវិញបានច្រើន ភ្ញៀវទេសចរណ៍កើនឡើងពីប្រហែល ១០% ទៅ ៥០%។ អាជ្ញាធរមូលដ្ឋាន និងសមាជិកគណៈកម្មការមានកិច្ចសហការល្អ ប្រជាពលរដ្ឋមានលទ្ធភាពប្រកបមុខរបរដូចជា ដាំដំណាំ និងចិញ្ចឹមមាន់។ សហគមន៍ក៏បានពង្រីកការដាំដុះដោយខ្លួនឯង និងអាចផ្គត់ផ្គង់តម្រូវការគ្រួសារបានប្រសើរឡើង។

## ៥. ការប្តេជ្ញាចិត្តរបស់លោក ជួន សំអាត ជំទប់ទី១ ឃុំក្បាលទឹក

ក្នុងនាមជាអាជ្ញាធរមូលដ្ឋាន លោកនឹងបន្តកិច្ចសហការជួយកសាងផ្លូវបន្ថែម ដើម្បីសម្រួលការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍មកទស្សនាធនធានធម្មជាតិ ដោយប្រើមូលនិធិឃុំ។ លោកនឹងបន្តពង្រឹងសន្តិសុខ និងសុវត្ថិភាព ដើម្បីឱ្យភ្ញៀវមានទំនុកចិត្តក្នុងការមកទស្សនា។ លោកក៏បន្តគាំទ្រដំណើរការរបស់ក្រុមសន្សំ តាមដានស្ថានភាពនានាក្នុងសហគមន៍ជាប្រចាំ និងរៀបចំកិច្ចប្រជុំជាមួយសហគមន៍យ៉ាងហោចណាស់ ៤ ដងក្នុងមួយឆ្នាំ ដើម្បីពង្រីកក្រុមសន្សំបន្ថែម និងអភិវឌ្ឍឱ្យក្លាយជាគំរូសម្រាប់សហគមន៍ផ្សេងៗអាចរៀនសូត្របាន។ លើសពីនេះ លោកនឹងពិចារណាដាក់ផែនការសកម្មភាពសហគមន៍បញ្ចូលក្នុងផែនការវិនិយោគឃុំផងដែរ។

## សំណូមពរ និងអនុសាសន៍

ជាចុងក្រោយ លោក ជួន សំអាត បានថ្លែងអំណរគុណដល់អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ និងគម្រោង GEF ដែលបានផ្តល់ការគាំទ្រចំគោលដៅប្រមាណ ៩០%។ លោកបានសំណូមពរឱ្យអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ និងគម្រោង GEF បន្តការគាំទ្រដល់សហគមន៍ព្រៃធំអន្លង់ថ្ម រហូតដល់មានភាពរឹងមាំ និងអាចដំណើរការដោយខ្លួនឯងបាន។ ព្រមទាំងស្នើសុំឱ្យពង្រីកការគាំទ្រទៅកាន់សហគមន៍ទាំង ៤ ក្នុងឃុំទាំងមូល រួមមាន ព្រៃធំអន្លង់ថ្ម អន្លង់ស្វាយ ម៉ាណុង និងខ្សាច់ពូន។

**រៀបចំដោយ៖ លោកស្រី ជួប ចន្ទី** ក្រុមអ្នកវាយតម្លៃឯករាជ្យ ART